សុន្ទរកថារបស់ **លោក ម៉ាជីដា តាស៊ីយ៉ា** ទីប្រឹក្សាស្ថានទូតជប៉ុនប្រចាំកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិរបស់ប្រទេសជប៉ុន

២៨ មិនា ២០១២

**សូមគោរព ឯឧត្តម ពេជ្រ វាសនា នាយកមជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ និងឧតុនិយម!**
**សូមគោរព លោក ឡុង ផលគុណ ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តបាត់ដំបង!**
**សូមគោរព លោក អ៊ឹង ស្វាង មេឃុំវត្តតាមិម!**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយជាមួយមន្ទីរធនធានទឹក និងឧតុនិយមខេត្តបាត់ដំបងសម្រាប់គម្រោងស្តារប្រព័ន្ធស្រោចស្រពត្នោតពងក្នុងខេត្តបាត់ដំបង។

រដ្ឋាភិបាលជប៉ុនបានយកចិត្តទុកដាក់ទៅលើវិស័យកសិកម្មយ៉ាងខ្លាំង តួយ៉ាងការផ្តល់ជំនួយឧបត្ថម្ភគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ។ ការកែលម្អប្រព័ន្ធធារាសាស្ត្របានជួយគាំទ្រដល់គោលនយោបាយរបស់រដ្ឋាភិបាលកម្ពុជាក្នុងការជំរុញផលិតកម្មស្រូវ និងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រនៅតាមតំបន់ជនបទ។

ជំនួយថ្ងៃនេះនឹងជួយឲ្យមន្ទីរធនធានទឹកនិងឧតុនិយមខេត្តបាត់ដំបងអាចស្តារនិងជួសជុលប្រឡាយកម្រិតបីមួយខ្សែប្រវែង៣,០៥០ម៉ែត្រ និងសាងសង់សំណង់ទម្លាក់ទឹក។ យើងរំពឹងថា វានឹងជួយកាត់បន្ថយការខូចខាតបណ្តាលមកពីទឹកជំនន់ដែលកើតមានឡើងជារៀងរាល់ឆ្នាំ ព្រមទាំងជួយធ្វើឲ្យប្រសើរឡើងនូវការទទួលបានទឹកស្រោចស្រពរបស់ប្រជាកសិករប្រមាណ ៣,១៨៨គ្រួសារនៅក្នុងតំបន់។

ខ្ញុំសង្ឃឹមថាគម្រោងដែលបានចុះហត្ថលេខានៅថ្ងៃនេះនឹងត្រូវបានអនុវត្តយ៉ាងរលូននិងថែទាំយ៉ាងត្រឹមត្រូវដោយមន្ទីរធនធានទឹក និងឧតុនិយមខេត្តបាត់ដំបង។ ខ្ញុំក៏សង្ឃឹមផងដែរថា គម្រោងនេះនឹងរួមចំណែកបង្កើនផលិតកម្មស្រូវ ព្រមទាំងជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាកសិករក្នុងតំបន់គោលដៅ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាព រវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!